រៀបចំដោយ

គាំទ្រដោយ

# ព្រឹត្តិបត្រពាណិជ្ជកម្ម
# iTrade Bulletin

## Inside

Infographic

"Understanding Business Registration in Cambodia"

"ស្វែងយល់ពីការចុះបញ្ជីពាណិជ្ជកម្មនៅកម្ពុជា"

ភាគ ០១ | លេខ ០១ | ខែកុម្ភៈ ឆ្នាំ២០២៥
VOLUME 01 | ISSUE 01 | FEBRUARY 2025

# ស្វែងយល់ពី ការចុះបញ្ជីពាណិជ្ជកម្មនៅកម្ពុជា



ដើម្បីដំណើរការអាជីវកម្មស្របច្បាប់ក្នុងប្រទេសកម្ពុជាម្ចាស់អាជីវកម្មត្រូវចុះបញ្ជីអាជីវកម្មនៅក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានពន្ធដារ(GDT) ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ(MLVT) និងបេឡាជាតិសន្តិសុខសង្គម(ប.ស.ស) តាមរយៈថ្នាលបច្ចេកវិទ្យាព័ត៌មាន (https://registrationservices.gov.kh) ដោយឡែកអាជីវកម្មមួយចំនួនអាចស្នើសុំអាជ្ញាប័ណ្ណ/លិខិតអនុញ្ញាតពីក្រសួង-ស្ថាប័នជំនាញបន្ថែមទៀតបាន។

## ហេតុអ្វី បានជាអ្នកគួរចុះបញ្ជីក្រុមហ៊ុនរបស់អ្នក ?

- បង្កើតអត្តសញ្ញាណផ្ទាល់ខ្លួនសម្រាប់អាជីវកម្ម
- ទទួលបានការគាំពារ តាមផ្លូវច្បាប់
- ទាក់ទាញអតិថិជន(ក្រុមហ៊ុនធំ) ដែលបញ្ជាទិញក្នុងទំហំធំ ព្រោះគ្មានក្រុមហ៊ុនធំណាចង់ រកស៊ីជាមួយអាជីវកម្មដែលមិនចុះបញ្ជីនោះទេ
- ជួយសម្រួលដល់ការទទួលកម្ចីប្រាក់ពីធនាគារ និងការវិនិយោគពីវិនិយោគិន
- ទទួលបានអត្ថប្រយោជន៍ផ្សេងៗសម្រាប់និយោជិតរបស់អ្នកពីបេឡាជាតិសន្តិសុខសង្គម
- បំពេញកាតព្វកិច្ចជាពលរដ្ឋក្រោមច្បាប់ និងបទប្បញ្ញត្តិនៃប្រទេសកម្ពុជា
- ជៀសវាងការផាកពិន័យផ្សេងៗនិងការតម្រូវឱ្យបិទទ្វារ អាជីវកម្ម

## តើត្រូវ ចំណាយពេល ប៉ុន្មានដើម្បីចុះបញ្ជីអាជីវកម្ម ?

នីតិវិធីនៃការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានអាចចំណាយពេល **៨ ថ្ងៃ** នៃថ្ងៃធ្វើការ៖

**៣ ថ្ងៃ** ដើម្បីទទួលបានវិញ្ញាបនបត្រឌីជីថលពីក្រសួងពាណិជ្ជកម្ម

**៤ ថ្ងៃ** ដើម្បីទទួលបានវិញ្ញាបនបត្រឌីជីថលពីអគ្គនាយកដ្ឋានពន្ធដារ

**១ ថ្ងៃ** ដើម្បីទទួលបានវិញ្ញាបនបត្រឌីជីថលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងប.ស.ស

## តើ អាជីវកម្ម មានប៉ុន្មានប្រភេទ ?

### ទម្រង់ក្រុមហ៊ុន-សហគ្រាស

| ក្រុមហ៊ុនមូលធន | ក្រុមហ៊ុនសហកម្មសិទ្ធិ | ក្រុមហ៊ុនបរទេស | |
|---|---|---|---|
| ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត | ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ | សាខាក្រុមហ៊ុនបរទេស | សហគ្រាសឯកបុគ្គល |
| ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត | ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត | ការិយាល័យតំណាងពាណិជ្ជកម្ម | |

## ឯកសារ តម្រូវសម្រាប់ចុះបញ្ជីក្រុមហ៊ុនមូលធន

**នាមករណ៍ក្រុមហ៊ុន**

**កម្មវត្ថុអាជីវកម្ម**

(កម្មវត្ថុមួយស្មើនឹងប័ណ្ណប៉ាតង់មួយ)

**ទីស្នាក់ការ**

- លេខទូរស័ព្ទ និងអ៊ីម៉ែល
- កិច្ចសន្យាជួល / ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ

**ព័ត៌មានម្ចាស់ហ៊ុន**

- អត្តសញ្ញាណបណ្ណ សម្រាប់ជនជាតិខ្មែរ
- លិខិតឆ្លងដែន សម្រាប់ជនបរទេស
- អាសយដ្ឋានម្ចាស់ហ៊ុន
- លេខទូរស័ព្ទ និងអ៊ីម៉ែល
- រូបថតបច្ចុប្បន្នមិនឱ្យលើសពី ៣ខែ (រូបថតទំហំ 4x6 និងផ្ទៃខាងក្រោយពណ៌ស)
- លក្ខន្តិកៈក្រុមហ៊ុន
- ករណី ម្ចាស់ហ៊ុនជានីតិបុគ្គល
  - លិខិតប្រគល់សិទ្ធិពីក្រុមហ៊ុនមេ*
  - វិញ្ញាបនបត្រក្រុមហ៊ុនមេ*
  - លក្ខន្តិកៈក្រុមហ៊ុនមេ*

**ដើមទុន**

**ករណី ម្ចាស់ភាគហ៊ុនលើសពីម្នាក់**

ក្រុមហ៊ុនត្រូវមានការបែងចែកភាគហ៊ុនទៅតាមចំនួន ឬប្រភេទភាគហ៊ុន

**មានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន**

**លិខិតប្រគល់សិទ្ធិ**

ករណីអ្នកតំណាងជាអ្នកបំពេញពាក្យស្នើសុំ

**កំណត់សម្គាល់៖ នីតិវិធីក្រោយការចុះបញ្ជី**

ក្រុមហ៊ុនត្រូវមានកាតព្វកិច្ចតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំតាមប្រព័ន្ធស្វ័យប្រវត្តកម្មជាមួយក្រសួងពាណិជ្ជកម្ម

** សម្រាប់ព័ត៌មានបន្ថែម
សូមទាក់ទងមកកាន់លេខទូរស័ព្ទទំនាក់ទំនងសាធារណៈ: **1266**

**រៀបចំដោយ**

**គាំទ្រដោយ**

**កូដ QR សម្រាប់ទាញយកឯកសារចុះបញ្ជីពាណិជ្ជកម្ម**

(ប្រភព៖ សៀវភៅមគ្គុទ្ទេសក៍ដំណើរការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន បោះពុម្ពលើកទី៣, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, មិថុនា ២០២៣)

Understanding

# BUSINESS REGISTRATION in CAMBODIA



To conduct legitimate business in Cambodia, business owners must register their business with the Ministry of Commerce, the General Department of Taxation (GDT), the Ministry of Labour and Vocational Training (MLVT) and National Social Security Fund (NSSF) via information technology platform (https://registrationservices.gov.kh). However, some businesses may require licenses / permits from specialized ministries.

## WHY should you register your company?

- Create personal identity for your business
- Receive legal protection
- Attract corporate customers because no corporate company wants to do business with unregistered business
- Ease your access to bank loan and investment
- Get benefits for your employees from National Social Security Fund
- Fulfill your obligation as a citizen under Cambodian laws and regulations
- Avoid fines and business closure

## HOW LONG does it take to get a business registered?

The new online business registration procedure takes up to **8** working days:

**3 days** to get a digital certificate from the Ministry of Commerce

**4 days** to get a digital certificate from General Department of Taxation (GDT)

**1 day** to get a digital certificate from General Department of Taxation (GDT)



## What DOCUMENTS are required to register a company?

### Name of Company

### Objective of Business

(One objective equals one patent)

### Head Office

- Telephone and Email
- Rental Agreement / Land Certificate

### Shareholder's Information

- ID Card for Khmer
- Passport for Foreigner
- Shareholder's Address
- Telephone and Email
- Current photo of no longer than 3 months (Photo Size 4x6 and White Background)
- Articles of Association
- If shareholder is a legal entity
  - Parent company's authorization letter*
  - Parent company's certificate*
  - Parent company's articles of association*

### Capital

### If More Than One Shareholder

company must divide the shares according to the number or type of shares

### Company Board of Directors

### Authorization Letter

if the one who fills out the application is your representative

## How many different types of BUSINESSES exist?

### Forms of Company - Enterprises

| Company | Partnership | Foreign Company | |
|---|---|---|---|
| Private Limited Company | General Partnership Company | Foreign Branch Office | Sole Proprietorship |
| Public Limited Company | Limited Partnership Company | Commercial Representative Office | |

**NOTE : Post-Registration Procedure**

Companies are required to submit the annual declaration via automation system with the Ministry of Commerce

** For more information, please contact the Ministry of Commerce Call Center 1266

Organized by

Supported by

**QR Code for Download Business Registration Documents**

(Source: User Guide How to Register Your Business Online. Third Edition, Ministry of Economy and Finance, June 2023)

## កម្ពុជា និងអូស្ត្រាលី ចុះអនុស្សរណៈនៃការយោគយល់ជំរុញការនាំចេញ

វិស័យឯកជនកម្ពុជា និងអូស្ត្រាលីបានចុះអនុស្សរណៈនៃការយោគយល់គ្នាចំនួនបី ដើម្បីជំរុញ និងសម្រួលដល់ការនាំចេញផលិតផលកម្ពុជាទៅកាន់ទីផ្សារអូស្ត្រាលី។ អនុស្សរណៈនៃការយោគយល់គ្នា ត្រូវបានចុះហត្ថលេខានៅទីក្រុងស៊ីដនី ប្រទេសអូស្ត្រាលី ក្រោមអធិបតីភាព**លោកជំទាវ ចម និម្មល** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។ ក្នុងសេចក្តីប្រកាសព័ត៌មានបានឱ្យដឹងថា "អនុស្សរណៈទាំងនេះមានបំណងលើកកម្ពស់ និងសម្រួលដល់ការនាំចេញផលិតផលកម្ពុជា ដែលមានដូចជាអង្ករ និងគ្រាប់ស្វាយចន្ទី ទៅកាន់ទីផ្សារអូស្ត្រាលី"។ យោងតាមរបាយការណ៍ក្រសួងពាណិជ្ជកម្ម ការនាំចេញរបស់កម្ពុជាទៅកាន់អូស្ត្រាលីមានតម្លៃជិត ៥៩៨ លានដុល្លារ ក្នុងឆ្នាំ២០២៤ កើន១៩,២% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ហើយការនាំចេញរបស់កម្ពុជាទៅអូស្ត្រាលីបានកើនឡើង ៣១% ស្មើប្រមាណ ៤៨៧ លានដុល្លារ។ *ប្រភព៖ Khmer Times*

## កម្ពុជានៅតែមានសុទិដ្ឋិនិយមចំពោះការនាំចេញទំនិញទៅទីផ្សារអាម៉េរិក

នៅខែមករា ឆ្នាំ២០២៥ កម្ពុជារកចំណូលបានជិត ៨៧០លានដុល្លារ ពីការនាំទំនិញទៅទីផ្សារអាម៉េរិក។ ទិន្នន័យអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា (GDCE) បានឱ្យដឹងថា ក្នុងខែមករា ឆ្នាំ២០២៥ ទំហំពាណិជ្ជកម្មរវាងកម្ពុជា អាម៉េរិក មានទឹកប្រាក់សរុប ៨៩២,៤៧លានដុល្លារ កើនឡើង ៣៨,៦% បើធៀបខែមករា ឆ្នាំ២០២៤ ក្នុងនោះទំនិញកម្ពុជានាំចេញទៅអាម៉េរិក មានតម្លៃ ៨៦៨,៧លានដុល្លារ កើនឡើង ៣៨,៦% ចំណែកទំនិញអាម៉េរិកនាំចូលមកកម្ពុជាវិញមានតម្លៃ ២៣,៧៦ លានដុល្លារ កើនឡើង ៣៧,៧%។ ផ្អែកតាមតួលេខជញ្ជីងពាណិជ្ជកម្មកម្ពុជាមានឧត្តមភាព ៨៤៤,៩៤លានដុល្លារ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៤ មានចំនួន ៦០៩,៥៧លានដុល្លារ។ អាម៉េរិក គឺជាទីផ្សារធំនៃការនាំចេញរបស់កម្ពុជាជាពិសេសផលិតផល សម្លៀកបំពាក់ កាបូបធ្វើដំណើរ ស្បែកជើង និងបន្ទះសូឡា។ *ប្រភព៖ The Phnom Penh Post*

## សហភាពអឺរ៉ុបនឹងបន្តផ្តល់ការអនុគ្រោះពាណិជ្ជកម្មដល់កម្ពុជាបីឆ្នាំបន្ថែមទៀតបន្ទាប់ពីកម្ពុជាចាកចេញពី LDC

មន្ត្រីជាន់ខ្ពស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានថ្លែងថា សហភាពអឺរ៉ុប នឹងបន្តប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មរបស់ខ្លួនសម្រាប់កម្ពុជារយៈពេលបីឆ្នាំទៀតបន្ទាប់ពីកម្ពុជានឹងចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច។ ថ្លែងក្នុងកម្មវិធីសន្និសីទ ឯកឧត្តម ផាន់ ផល្លា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបញ្ជាក់ថា "សហភាពអឺរ៉ុបនឹងមិនបញ្ចប់ប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មភ្លាមៗនោះទេ, សហភាពអឺរ៉ុបនឹងបន្តផ្តល់ជំនួយបីឆ្នាំទៀតរហូតដល់ឆ្នាំ២០៣២"។ របាយការណ៍ក្រសួងពាណិជ្ជកម្មបានឱ្យដឹងថា កាលពីឆ្នាំ២០២៤ កម្ពុជាបាននាំចេញទំនិញមានតម្លៃ ៤,៤១ ប៊ីលានដុល្លារ ទៅកាន់សហភាពអឺរ៉ុប កើនឡើង ២០,៣៤% ពោលគឺកើនពី ៣,៦៦លានដុល្លារ ដែលបានកត់ត្រាក្នុងឆ្នាំ២០២៣។ ទំហំពាណិជ្ជកម្មរវាងកម្ពុជានិងសហភាពអឺរ៉ុបមានប្រមាណ ៩,៦២% នៃទំហំពាណិជ្ជកម្មសរុបដែលមានតម្លៃស្មើនឹង ៥៥,៣៧ ប៊ីលានដុល្លារ។ *ប្រភព៖ Khmer Times*

## ធនាគារជាតិនៃកម្ពុជារៀបចំសិក្ខាសាលាផ្សព្វផ្សាយគោលការណ៍ហិរញ្ញវត្ថុបៃតង

ធនាគារជាតិនៃកម្ពុជាបានរៀបចំសិក្ខាសាលាស្តីពីសារៈសំខាន់នៃការលើកកម្ពស់គោលការណ៍ហិរញ្ញវត្ថុបៃតងសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពរបស់កម្ពុជា ក្រោមប្រធានបទ "ទំនាក់ទំនងអន្តរកម្ម និងផលប៉ះពាល់នៃការវិនិយោគផ្នែកបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) លើវិស័យសេដ្ឋកិច្ចដែលគ្មានការបំភាយឧស្ម័នកាបូន ក្នុងអាស៊ាន និងសិង្ហបុរី"។ លោកសាស្ត្រាចារ្យ Shandre Mugan Thangavelu ប្រធានវិទ្យាស្ថាន Jeffrey Cheah (JCI) សម្រាប់អាស៊ីអាគ្នេយ៍នៅសាកលវិទ្យាល័យ Sunway ប្រទេសម៉ាឡេស៊ី បានធ្វើបទបង្ហាញអំពីសារៈសំខាន់នៃការចូលរួមលើកកម្ពស់គោលការណ៍ហិរញ្ញវត្ថុបៃតង ឆ្ពោះទៅរកការសម្រេចបាននូវសេដ្ឋកិច្ចដែលគ្មានការបំភាយឧស្ម័នកាបូន។ លោកសាស្ត្រាចារ្យបានកត់សម្គាល់ថា "ភាគីពាក់ព័ន្ធទាំងអស់មានតួនាទីសំខាន់ក្នុងការជំរុញការអភិវឌ្ឍប្រកបដោយចីរភាព ហើយការអនុវត្តគោលការណ៍បៃតងក៏នឹងជះឥទ្ធិពលជាវិជ្ជមានដល់ប្រាក់ចំណេញរបស់ក្រុមហ៊ុនផងដែរ"។ *ប្រភព៖ Khmer Times*

## Cambodia, Australia Ink MoUs to Promote Exports

Cambodian and Australian private sectors signed three memorandums of understanding to promote and facilitate the export of Cambodian products to the Australian market. The MoU was signed in Sydney, Australia, in the presence of **Cham Nimul,** Minister of Commerce. “These MoUs aim to promote and facilitate the export of Cambodian products, such as rice and cashew nuts, to the Australian market,” said in a statement issued following the signing ceremony. Cambodia’s exports to Australia were valued at nearly $598 million in 2024, marking a 19.2 percent increase compared to the same period in the previous year, according to a recent report from the Ministry of Commerce. The Kingdom’s export to Australia rose by 31 percent to $487 million, read the report.
***Source: Khmer Times***

## Despite Trade War, Insiders Optimistic About US Export Market

In January, Cambodia earned nearly $870 million from exports to the US. The General Department of Customs and Excise (GDCE) reported that last month, trade between Cambodia and the US reached a total value of $892.47 million, an increase of 38.6% over January 2024. Of this figure, exports to the US were valued at $868.7 million, up 38.6%, while US imports amounted to $23.76 million, up 37.7%. The figured reveal that Cambodia’s trade balance was positive, amounting to $844.94 million, compared to $609.57 million in the same period in 2024. The US has consistently been a major market for Cambodian goods, especially apparel, travel bags, footwear and solar panels. ***Source: The Phnom Penh Post***

## EU to Extend Cambodia’s Trade Preference Benefits by Three More Years After LDC Graduation

The European Union (EU) will extend its trade preference scheme for Cambodia for three years after the country graduates from its Least Developed Country (LDC) status, a senior official from the Ministry of Economy and Finance stated. “The European Union will not immediately end its trade preference. The EU grants us another three years, until 2032,” Phan Phalla remarked at a conference. Last year, Cambodia exported $4.41 billion worth of goods to the European Union (EU), marking a 20.34 percent increase from $3.66 million recorded in 2023, according to a report from the Ministry of Commerce. The country’s trade with the EU accounted for 9.62 percent of the total trade, amounting to $55.37 billion, it added.
***Source: Khmer Times***

## NBC Hosts Seminar to Promote Green Finance Principles

The National Bank of Cambodia (NBC) hosted a seminar to highlight the importance of actively promoting green finance principles for the Kingdom’s sustainable development. The seminar themed ‘Interlinkages and Impacts of Environmental, Social and Governance (ESG) Investments on Net Zero Economy in ASEAN and Singapore’. Shandre Mugan Thangavelu, Head of Jeffrey Cheah Institute (JCI) for Southeast Asia at Sunway University, Malaysia, presented the importance of participation in the promotion of green finance principles toward achieving a net zero economy. “All stakeholders have an essential role in advancing sustainable development and implementing green principles will also positively impact corporate profits,” he noted.
***Source: Khmer Times***

## តើអ្វីទៅជាផែនការពន្ធគយ 'បដិការ' របស់លោកប្រធានាធិបតី Donald Trump ?

ផែនការពន្ធគយ "បដិការ" របស់លោកប្រធានាធិបតី Donald Trump កំណត់គោលដៅលើការអនុវត្តពាណិជ្ជកម្មមិនស្មើភាពដោយការដាក់ពន្ធលើប្រទេសដែលមានរបាំងមិនមែនពន្ធដូចជា VAT និងពន្ធសេវាកម្មឌីជីថល។ អាម៉េរិកមានបំណងផ្តួចផ្តើមការយកពន្ធលើទំនិញរបស់អាម៉េរិកជាមួយប្រទេសផ្សេងទៀតជាប្រទេសគោលដៅរួមមាន ជប៉ុន ឥណ្ឌា សហភាពអឺរ៉ុប និងប្រេស៊ីល ដែលអាចនឹងបំពានច្បាប់ WTO។ ខណៈដែលផែនការនេះអាចនាំឱ្យមានការដាក់ពន្ធខ្ពស់ លោក Trump នឹងបន្ថយពន្ធប្រសិនបើដៃគូពាណិជ្ជកម្មរបស់អាម៉េរិកកាត់បន្ថយអត្រាពន្ធរបស់ពួកគេដែរ។ *ប្រភព៖ Financial Times*

## 'អង្គការពាណិជ្ជកម្មពិភពលោកគឺបរាជ័យ' តើមានអ្វីកើតឡើងចំពោះពាណិជ្ជកម្មសកលលោកនាពេលបច្ចុប្បន្ន

គោលនយោបាយពន្ធគយថ្មីរបស់លោកប្រធានាធិបតី Trump ប្រជែងជាមួយនឹងប្រព័ន្ធពាណិជ្ជកម្មសេរីសកលដែលត្រូវបានបង្កើតឡើងក្រោយសង្គ្រាមលោកលើកទី២ ដោយគំរាមកំហែងដល់តួនាទីរបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO)។ តាមរយៈការដាក់ពន្ធគយឯកតោភាគី លោក Trump មានគោលបំណងកែប្រែគោលនយោបាយពាណិជ្ជកម្មរបស់អាម៉េរិក ដោយលើកហេតុផលថា ច្បាប់បច្ចុប្បន្នផ្តល់ការអនុគ្រោះច្រើនដល់ប្រទេសនាំចេញ ដូចជាប្រទេសចិន។ ចំណាត់ការរបស់គាត់អាចនាំឱ្យមានការតបតជាសាកល និងការកើនឡើងនូវថ្លៃដើម ដែលធ្វើឱ្យប៉ះពាល់ដល់គោលការណ៍របស់ WTO។ ប្រព័ន្ធដោះស្រាយវិវាទរបស់ WTO នៅតែបិទខ្ទប់បន្ទាប់ពីលោក Trump បានរាំងការតែងតាំងចៅក្រមនៅក្នុងអាណត្តិដំបូងរបស់គាត់។ ប្រទេសកំពុងអភិវឌ្ឍន៍ ដែលទទួលបានអត្ថប្រយោជន៍ពីពន្ធគយខ្ពស់ និងការឧបត្ថម្ភធន អាចប្រឈមមុខនឹងវិធានការតបតរបស់អាម៉េរិក។ ជំហាននេះជាសញ្ញានៃការផ្លាស់ប្តូរមួយចេញពីកិច្ចព្រមព្រៀងពាណិជ្ជកម្មពហុភាគីដ៏មានសក្តានុពលឆ្ពោះទៅពាណិជ្ជកម្មពិភពលោកដែលគ្មានសណ្តាប់ធ្នាប់ជាងមុន។

*ប្រភព៖ The New York Times*

## ខណៈប្រទេសជាច្រើនផ្លាស់ប្តូរទីតាំងវិនិយោគ អាស៊ានគួរផ្តោតលើពាណិជ្ជកម្ម ឌីជីថលភាវូបនីយកម្ម និងការតភ្ជាប់

អាស៊ានគួរតែផ្តោតលើពាណិជ្ជកម្ម ឌីជីថលភាវូបនីយកម្ម និងការតភ្ជាប់ដើម្បីលើកកម្ពស់ភាពធន់នឹងសេដ្ឋកិច្ចចំពេលសកលលោកមានភាពមិនប្រាកដប្រជា។ នៅពេលដែលប្រទេសនានាផ្លាស់ប្តូរខ្សែច្រវាក់ផ្គត់ផ្គង់ និងការដាក់ពន្ធគយ អាស៊ានត្រូវតែធ្វើការរួមគ្នាដើម្បីជំរុញកំណើនប្រកបដោយចីរភាព។ ពាណិជ្ជកម្មសេវាកម្ម មានដូចជាផ្នែកហិរញ្ញវត្ថុ ទូរគមនាគមន៍ និងទេសចរណ៍ នឹងក្លាយជាគន្លឹះមួយ ដែលការធ្វើដំណើរក្នុងតំបន់នឹងជួយជំរុញស្ថិរភាពសេដ្ឋកិច្ច។ សេដ្ឋកិច្ចឌីជីថលត្រូវបានគេរំពឹងថានឹងកើនឡើងយ៉ាងខ្លាំងនៅឆ្នាំ២០៣០ ដែលគាំទ្រដោយកិច្ចព្រមព្រៀងក្របខ័ណ្ឌសេដ្ឋកិច្ចឌីជីថល។ អាស៊ានគួរតែផ្តល់អាទិភាពដល់ហេដ្ឋារចនាសម្ព័ន្ធប្រកបដោយនិរន្តរភាព និងការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ដើម្បីគាំទ្រដល់គោលដៅនៃគ្មានការបំភាយឧស្ម័នកាបូនត្រឹមឆ្នាំ២០៥០។ *ប្រភព៖ Asian Development Blog*

## ការរៀបចំប្រទេសសម្រាប់សមាហរណកម្ម៖ មាគ៌ារបស់ប្រទេសទីម័រខាងកើតទៅកាន់អាស៊ាន

ទីម័រខាងកើតបានបោះជំហានសំខាន់ៗ ឆ្ពោះទៅរកការចូលជាសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ប៉ុន្តែបញ្ហាប្រឈមនៅតែមាន។ ការពង្រឹងអភិបាលកិច្ច ការជំរុញការវិនិយោគ ការពង្រីកពាណិជ្ជកម្ម និងការពង្រឹងធនធានមនុស្សនៅតែសំខាន់។ ទីម័រខាងកើតគឺជាប្រទេសប្រជាធិបតេយ្យវ័យក្មេង ដែលប្រឈមនឹងបញ្ហាអភិវឌ្ឍន៍សំខាន់ៗ។ អត្រានៃភាពក្រីក្រនៅតែមានកម្រិតខ្ពស់ ៤១,៨% ហើយកំណើនសេដ្ឋកិច្ចមានភាពប្រែប្រួល ដែលងាយរងផលប៉ះពាល់ដោយវិបត្តិខាងក្រៅ និងក្នុងស្រុក។ សេដ្ឋកិច្ចពឹងផ្អែកយ៉ាងខ្លាំងលើការចំណាយសាធារណៈ និងចំណូលពីប្រេងឥន្ធនៈ។ បញ្ហាប្រឈមក្នុងរចនាសម្ព័ន្ធយូរអង្វែង ដូចជាវិស័យឯកជនទន់ខ្សោយ ហេដ្ឋារចនាសម្ព័ន្ធមិនគ្រប់គ្រាន់ កង្វះកម្លាំងពលកម្មជំនាញ និងបរិយាកាសធុរកិច្ចស្មុកស្មាញ បង្ហាញពីឧបសគ្គដល់ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ចក្នុងរយៈពេលវែង។

*ប្រភព៖ Asian Development Blog*

## តើអាស៊ីអាចសម្របតាមគោលនយោបាយរដ្ឋបាលថ្មីរបស់សហរដ្ឋអាម៉េរិកដោយជោគជ័យដោយរបៀបណា?

ការដំឡើងពន្ធរបស់សហរដ្ឋអាម៉េរិកនិងគោលនយោបាយផ្សេងទៀតរបស់រដ្ឋបាលប្រធានាធិបតីអាម៉េរិកថ្មី អាចផ្តល់នូវលទ្ធផលចម្រុះសម្រាប់សេដ្ឋកិច្ចអាស៊ី ដោយសង្កត់ធ្ងន់លើសារៈសំខាន់នៃការកសាងភាពធន់តាមរយៈសមាហរណកម្មក្នុងតំបន់ និងពាណិជ្ជកម្មបើកចំហ។ ផលបច្ច័យអវិជ្ជមានលើសេដ្ឋកិច្ចចិននឹងមានកម្រិតតិចតួច ទោះបីជាមានការដាក់ពន្ធ៦០% ក៏ដោយ។ ការសិក្សាដំបូងដោយប្រើគំរូម៉ាក្រូ រកឃើញថាកំណើនសេដ្ឋកិច្ចថយចុះត្រឹមតែ ០,៣% ក្នុងមួយឆ្នាំក្នុងអំឡុងពេល៤ ឆ្នាំនៃរដ្ឋបាលថ្មី ហើយគំរូពាណិជ្ជកម្មព្យាករណ៍ពីផលប៉ះពាល់តិចតួច ដោយសារតែកាលានុវត្តភាព នៃការប្តូរទិសពាណិជ្ជកម្មទៅកាន់ប្រទេសផ្សេងទៀត។ ផលប៉ះពាល់នឹងមិនសូវជាធ្ងន់ធ្ងរ ករណីដែលសហរដ្ឋអាម៉េរិកដាក់ពន្ធបន្ថែម១០% ដូចដែលបានប្រកាសនាពេលថ្មីៗនេះ បើទោះបីជាការពិនិត្យឡើងវិញបន្ថែមទៀតអំពីអតុល្យភាពពាណិជ្ជកម្មរបស់សហរដ្ឋអាម៉េរិក អាចនាំឱ្យមានការដំឡើងពន្ធបន្ថែមទៀតនៅឆ្នាំក្រោយក៏ដោយ។ *ប្រភព៖* Asian Development Blog

## ពីផ្លូវក្លាយទៅជាភោគទ្រព្យៈច្រករបៀងសេដ្ឋកិច្ចអាចបង្កើនថាមពលអាស៊ីខាងត្បូង

ច្រករបៀងសេដ្ឋកិច្ច គឺជាបណ្តាញនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធ ដែលត្រូវបានរៀបចំឡើង ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ចនៅទូទាំងនិងរវាងតំបន់។ ច្រករបៀងទាំងនេះរួមបញ្ចូលផ្លូវដឹកជញ្ជូន ដូចជាផ្លូវហាយវេ ផ្លូវដែក និងកំពង់ផែ ក៏ដូចជាមជ្ឈមណ្ឌលឧស្សាហកម្ម និងតំបន់សម្របសម្រួលពាណិជ្ជកម្ម។ គោលបំណងគឺដើម្បីបង្កើនការតភ្ជាប់ កាត់បន្ថយរបាំងពាណិជ្ជកម្ម និងជំរុញការវិនិយោគ ដែលជំរុញសកម្មភាពសេដ្ឋកិច្ច និងការបង្កើតការងារ។ ច្រករបៀងសេដ្ឋកិច្ចគឺជាកត្តាជំរុញនៃកំណើនសេដ្ឋកិច្ច និងបរិវត្តកម្មរចនាសម្ព័ន្ធ ហើយមានសារៈសំខាន់ក្នុងការអភិវឌ្ឍក្នុងតំបន់ និងសមាហរណកម្មសេដ្ឋកិច្ច។ ច្រករបៀងសេដ្ឋកិច្ចមិនត្រឹមតែលើកកម្ពស់ការតភ្ជាប់ និងពាណិជ្ជកម្មប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជំរុញឧស្សាហូបនីយកម្ម ការបង្កើតការងារ និងកំណើនប្រកបដោយតុល្យភាពក្នុងតំបន់ផងដែរ។ ប្រទេសឥណ្ឌាដែលមានសេដ្ឋកិច្ចចម្រុះ និងធំ ដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍច្រករបៀងសេដ្ឋកិច្ចក្នុងប្រទេសបង់ក្លាដែស ប៊ូតាន នេប៉ាល់ និងស្រីលង្កា។ គំនិតផ្តួចផ្តើមជាយុទ្ធសាស្ត្ររបស់ប្រទេស ដូចជាកម្មវិធីអភិវឌ្ឍន៍ច្រករបៀងឧស្សាហកម្មជាតិ (NICDP) និងផែនការមេថ្នាក់ជាតិរបស់នាយករដ្ឋមន្ត្រី Gati Shakti មានបំណងលើកកម្ពស់ការតភ្ជាប់ និងលើកកម្ពស់សមាហរណកម្មសេដ្ឋកិច្ច។

*ប្រភព៖* Asian Development Blog

### What Is Donald Trump's 'Reciprocal' Tariff Plan?

Donald Trump's "reciprocal" tariff plan, targets unfair trade practices by imposing tariffs on countries with non-tariff barriers like VAT and digital services taxes. The U.S. aims to match tariffs imposed on U.S. goods by other countries, potentially breaking WTO rules. Key targets include Japan, India, the EU, and Brazil. While the plan could lead to higher tariffs, Trump is open to lowering them if trading partners reduce their own. ***Source: Financial Times***

### 'The W.T.O. Is Toast.' What Happens to Global Trade Now

Trump's new tariff policies challenge the global free trade system established post-World War II, threatening the role of the WTO. By imposing unilateral tariffs, Trump aims to reshape U.S. trade policy, arguing that current rules favor exporters like China. His move could lead to global retaliation and rising costs, undermining the WTO's principles. The WTO's dispute resolution system remains paralyzed after Trump blocked judge appointments in his first term. Developing countries, benefiting from high tariffs and subsidies, may face U.S. countermeasures. The move signals a potential shift away from multilateral trade agreements toward a more fragmented global trade order. ***Source: The New York Times***

### As Nations Reshore, ASEAN Should Explore Trade, Digitalization and Connectivity

ASEAN should focus on trade, digitalization, and connectivity to promote economic resilience amid global uncertainties. As countries reshoring supply chains and deploying tariffs, ASEAN must work together to foster sustainable growth. Services trade, particularly in finance, telecom, and tourism, will be key, with intra-regional travel helping boost economic stability. The digital economy is expected to grow significantly by 2030, supported by the Digital Economy Framework Agreement. ASEAN should prioritize sustainable infrastructure and cross-border logistics to support net-zero emissions goals by 2050. ***Source: Asian Development Blog***

### Preparing the Nation for Integration: Timor-Leste's Path to ASEAN

Timor-Leste is a young democracy facing significant development challenges. The poverty rate remains high at 41.8% and economic growth has been volatile, affected by both external and domestic shocks.Timor-Leste is a young democracy facing significant development challenges. The poverty rate remains high at 41.8% and economic growth has been volatile, affected by both external and domestic shocks.Timor-Leste is a young democracy facing significant development challenges. The poverty rate remains high at 41.8% and economic growth has been volatile, affected by both external and domestic shocks.The economy relies heavily on public spending and petroleum revenues. Long-standing structural challenges such as a weak private sector, inadequate infrastructure, a lack of skilled labor, and a challenging business environment, present daunting obstacles to economic diversification and long-term growth.

***Source: Asian Development Blog***

### How Can Asia Successfully Navigate New US Administration Policies?

Rising US tariffs and other policies of the new US presidential administration could create mixed outcomes for Asian economies, emphasizing the importance of building resilience through regional integration and open trade. The negative effects on the Chinese economy will be relatively modest even with 60% tariffs. The first study, using a macro model, finds that growth slows by just 0.3% per year during the four years of the new administration, and the trade model predicts much smaller impacts thanks to opportunities to redirect trade to other countries.The impacts will be even less severe if the US only imposes additional tariffs of 10% as has been recently announced, even though further review of US trade imbalances could lead to more tariff increases later in the year. ***Source: Asian Development Blog***

### From Roads to Riches: Economic Corridors Can Supercharge South Asia

An economic corridor is a network of infrastructure projects designed to stimulate economic development across and between regions. These corridors typically include transportation routes, such as highways, railways, and ports, as well as industrial hubs and trade facilitation zones. The aim is to enhance connectivity, reduce trade barriers, and promote investment, ultimately spurring economic activities and job creation. Economic corridors are drivers of economic growth and structural transformation and are integral to the pursuit of regional development and economic integration. They not only enhance connectivity and trade but also foster industrialization, job creation, and balanced regional growth. India, with its vast and diverse economy, plays a crucial role in the development of economic corridors in Bangladesh, Bhutan, Nepal and Sri Lanka. The country's strategic initiatives, such as the National Industrial Corridor Development Program (NICDP) and the Prime Minister Gati Shakti (PM-GS) National Master Plan, aim to enhance connectivity and promote economic integration. ***Source: Asian Development Blog***

# About the iTrade

iTrade Bulletin is an e-publication by the Trade Training and Research Institute of the Ministry of Commerce. This monthly bulletin provides brief updates on specific issues in Cambodia, the regions and the world.

This knowledge-sharing through scientific researches in the multifaceted areas aims to highlight current trade news & statistics relevant to all social stakeholders.


## Honorable President

H.E. Mrs. CHAM Nimul

## Editorial Board

- H.E. Dr. TAT Puthsodary (Chairman)
- H.E. Ms. SEREI Borapich
- Mr. HOR lengchhay
- Ms. PHAL Yita

## Advisor

- H.E. Mr. PENN Sovicheat
- H.E. Prof. Shandre Mugan THANGAVELU

## Teamwork

- Mr. PAO Phireak
- Mr. CHINKET Tola
- Ms. YANGNY Chakriya
- Mr. LY Rithy
- Mr. NY Atykunn
- Mr. KHAM Chansopheak



## Special Thanks

- Business Registration Department of the Ministry of Commerce


## Announcement

Academicians, researchers, students and public are welcome to contribute their academic works, on all disciplines and topics of relevant interest to trade, to the next publication of the iTrade Bulletin.

## Topics Covered:

- International trade and logistics / trade laws;
- Digital economy / e-commerce;
- Economics and economic laws;
- Value added supply chains and logistics; and
- Facilitate the green business transition

## Categories:

- Research articles
- Case reports
- Policy Briefs


## Trade Training and Research Institute

Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA

ttri.moc | www.ttri.moc.gov.kh | @ttrimoccambodia